**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ប្រ.ក/លេខ១១.០៤៤/០៧ គ.ជ.ប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០០៧

# បណ្តឹងរបស់តំណាងគណបក្សសម រង្ស៊ី ចំនួន ៨៥ បណ្តឹង ត្រូវបាន គ.ជ.ប ចារបដិសេធមិនដោះស្រាយ

នៅថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ គ.ជ.ប បានសម្រេចចារបដិសេធលើបណ្តឹងរបស់តំណាងគណបក្សសម រង្ស៊ី ចំនួន ៨៥ បណ្តឹង ដោយសារបណ្តឹងទាំងនេះហួសកាលកំណត់ ។

បណ្តឹងទាំង ៨៥ ដែល គ.ជ.ប ចារបដិសេធនេះ គឺតំណាង គណបក្សសម រង្ស៊ី បានប្តឹងបដិសេធសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ ក្នុងការសម្រេចលុបឈ្មោះអ្នកបោះឆ្នោតចេញពីបញ្ជីបោះឆ្នោតចុងក្រោយ នូវឈ្មោះអ្នកបោះឆ្នោតដែលមាននៅក្នុងទម្រង់ ១០២៥ នៅខេត្ត តាកែវ ចំនួន ៥១ បណ្តឹង ខេត្ត កំពង់ឆ្នាំង ចំនួន ៨ បណ្តឹង ខេត្ត បាត់ដំបង ចំនួន ១៩ បណ្តឹង និងខេត្ត បន្ទាយមានជ័យ ចំនួន ៧ បណ្តឹង។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា តំណាងគណបក្សសម រង្ស៊ី បានដាក់ពាក្យប្តឹងមិនបានត្រឹមត្រូវតាមនីតិវិធីនៃបណ្តឹង ។ តាមនីតិវិធីនៃបណ្តឹង ជនគ្រប់រូប ឬតំណាងមានសិទ្ធិដាក់ពាក្យប្តឹង ចំពោះមន្ត្រីបោះឆ្នោតថ្នាក់ក្រោមណា ដែលរំលោភលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ច.ប.ត.រ) និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ប.ន.ត.រ) ក្នុងរយៈពេល ៣ ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃកើតហេតុ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយ ច.ប.ត.រ។